សប្តាហ៍ទី
38

អ្នកស្រុកសាម៉ារីមានចិត្តសប្បុរស

ព្រះយេស៊ូស្រឡាញ់អ្នកជិតខាងរបស់យើង និងជួយពួកគេនៅពេលដែលជួបការលំបាក។ ពួកយើងក៏អាចជួយអ្នកដទៃដោយចិត្តសប្បុរស និងក្តីស្រឡាញ់!

រឿងក្នុងព្រះគម្ពីរ

មានបុរសម្នាក់កំពុងធ្វើដំណើរតាមផ្លូវ ស្រាបតែមានក្រុមចោរមកវាយប្លន់គាត់ហើយទុកគាត់ឱ្យរងរបួសយ៉ាងធ្ងន់ធ្ងរ។ មានបូជាចារ្យ និងក្រុមលេវីបានដើរមកឃើញគាត់ ប៉ុន្តែបានដើរហួសទៅ។
ប៉ុន្តែមានអ្នកស្រុកសាម៉ារីម្នាក់ដែលមកពីតំបន់ផ្សេងគ្នា មានចិត្តអាណិតដល់គាត់។ គាត់បានរុំរបួស និងមើលថែគាត់ ហើយថែមទាំងចេញថ្លៃកន្លែងស្នាក់នៅឱ្យគាត់ផងដែរ។
ព្រះយេស៊ូបានមានបន្ទូលអំពីរឿងនេះដើម្បីបង្រៀនដល់យើង។

«ត្រូវស្រឡាញ់អ្នកជិតខាង ឱ្យដូចស្រឡាញ់ខ្លួនឯង»។
(ម៉ាកុស 6:41~42)



វត្ថុបំណង

- រៀនបានពីក្តីស្រឡាញ់ និងការជួយអ្នកដទៃដោយក្តីស្រឡាញ់
- រៀនយកចិត្តទុកដាក់មើលថែ និងលួងលោមមិត្តភក្តិ
- រីករាយនឹងការធ្វើសម្ភារៈពេទ្យសម្រាប់លេង និងសម្តែងតួរ
- ទទួលបានបទពិសោធនៃសេចក្តីអំណរក្នុងការជួយអ្នកដទៃ។

សម្ភារៈ



របៀបធ្វើ

1. យកថង់ក្រដាសដែលរៀបចំរួចមកបិទសញ្ញាពេទ្យនៅចំកណ្តាលៗ
2. ជាត់ពណ៌រូបសម្ភារៈពេទ្យនៅលើក្រដាសពុម្ពដែលបានព្រីន
3. កាត់រូបសម្ភារៈពេទ្យដែលបានជាត់ពណ៌រួចចេញដោយប្រើកន្ត្រៃ
4. យករូបសម្ភារៈខ្លះទៅបិទកាវនៅលើថង់ ដើម្បីតុបតែងថង់ក្រដាស
5. យករូបសម្ភារៈដែលនៅសល់ទុកក្នុងថង់ក្រដាសនោះ
6. កាបូបពេទ្យរបស់យើងរួចរាល់! តស់ទៅលេងជាមួយមិត្តភក្តិ។



ការពង្រីកសកម្មភាព

- លេងធ្វើពេទ្យ ហើយព្យាបាលមិត្តភក្តិរបស់អ្នក
- សម្តែងធ្វើជាវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិកា
- បង្កើតសម្ភារៈពេទ្យបន្ថែមទៀត ហើយបង្កើតជារឿងនិទាន
- សកល្បងដើរតួជា៖ អ្នកជំងឺ វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិកា និងអ្នកជួយ។



Tip សម្រាប់គ្រូ

- សកម្មភាពនេះជួយកុមារឱ្យអភិវឌ្ឍការយល់ចិត្តអ្នកដទៃ និងស្មារតីនៃការចេះយកចិត្តទុកដាក់មើលចែ។
- តាមរយៈការលេងដើរតួ កុមារអាចរៀនពីការបង្ហាញសេចក្តីសប្បុរសតាមបែបធម្មជាតិ។
- សូមលើកទឹកចិត្តកុមារឱ្យគិតពីវិធីតូចៗដែលពួកគេអាចជួយអ្នកដទៃនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។
- សូមសរសើរ និងទទួលស្គាល់ការយកចិត្តទុកដាក់របស់ពួកគេ។

